**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ១៥៤/២៣ .............អអរ**

## សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តមណ្ឌលគិរី"

នាព្រឹកថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តមណ្ឌលគិរី»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ស៊ិន សារុន អភិបាលរង នៃគណៈអភិបាលខេត្តមណ្ឌលគិរី**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តមណ្ឌលគិរី**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តមណ្ឌលគិរី ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## I. ស្ថានភាពទូទៅ

ខេត្តមណ្ឌលគិរី បែងចែកចេញជា ក្រុង១ ស្រុក៤ ឃុំ១៧ សង្កាត់៤ និងភូមិ៩២ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ៩៧.៥៦២នាក់ ស្មើនឹង ២៣.៥៤០គ្រួសារ ក្នុងនោះ មានជនជាតិដើមភាគតិច ៨ជនជាតិ ស្មើនឹង ៥៥% នៃប្រជាពលរដ្ឋសរុបក្នុងខេត្ត។ ទំហំសេដ្ឋកិច្ចខេត្តមានចំនួនប្រមាណ ១៦៤លានដុល្លារអាមេរិក ស្មើនឹង ១.៣% នៃសេដ្ឋកិច្ចជាតិ ខណៈចំណូលជាមធ្យមរបស់មនុស្សម្នាក់ស្មើនឹង ១.៦៨៧ដុល្លារអាមេរិក ដោយពឹងផ្អែកលើមុខរបរកសិកម្ម៨២% សិប្បកម្ម១% និងសេវាកម្ម១៧%។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះចំនួន ៧.៩២០គ្រួសារ ចំណាយទឹកប្រាក់សរុបចំនួន ២៧.៧៨៥.៩៩២.០០០រៀល, ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ចំណាយថវិកាចំនួន ៧៣២.៣៦០.០០០រៀល, ឧបត្ថម្ភជូនគ្រួសារងាយរងហានិភ័យដោយសារសម្ពាធអតិផរណាចំនួន ១.៤៨៤គ្រួសារ ចំណាយថវិកា ២១៩.២៨១.២០០រៀល។
- **វិស័យកសិកម្ម៖** ប្រជាពលរដ្ឋទូទាំងខេត្ត ផ្តោតសំខាន់លើការងារកសិកម្មជាចម្បង ដោយសារលក្ខណៈដីមានជីវជាតិអំណោយផលដល់ដំណាំកសិកម្ម និងដំណាំកសិ-ឧស្សាហកម្មនានា ក្នុងនោះ ដំណាំស្រូវ បានអនុវត្តលើផ្ទៃដីទំហំ ២៩.៣៦៤ហិកតា, បន្លែ ដំណាំហូបផ្លែ និងដំណាំរួមផ្សំ ២.០៨៣ហិកតា ដំណាំឧស្សាហកម្ម ១៥.៤៤៩ហិកតា ជាពិសេសការវិនិយោគលើដំណាំកៅស៊ូ ដោយបច្ចុប្បន្ននេះ ទូទាំងខេត្តមានដំណាំកៅស៊ូសរុបចំនួន ៤២.៥៣៧,៤១ហិកតា។ ជាមួយគ្នានេះ រដ្ឋបាលខេត្តបានធ្វើការសាងសង់ និងជួសជុលជាបន្តបន្ទាប់ទៅលើប្រព័ន្ធធារាសាស្ត្រ ក្នុងន័យទ្រទ្រង់នូវការផ្គត់ផ្គង់ទឹក ជំរុញទិន្នផលកសិកម្ម ឱ្យមានការកើនឡើងជាលំដាប់ បើប្រៀបធៀបទៅនឹងឆ្នាំកន្លងទៅ។
- **ការងារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពបានយ៉ាងល្អប្រសើរ។ ជាមួយគ្នានេះ ដោយឈរលើស្មារតីកិច្ចសហប្រតិបត្តិការល្អ សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់នៅតាមខ្សែបន្ទាត់ព្រំដែនរក្សាបាននូវសន្តិភាព សាមគ្គីភាព មិត្តភាព និងការពារអធិបតេយ្យភាព បូរណភាពទឹកដី និងការអភិវឌ្ឍ។
- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានស្ថាបនា និងថែទាំជាប្រចាំទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់។ ដោយបច្ចុប្បន្ននេះ ផ្លូវក្នុងខេត្តសរុបមានប្រវែង ៨៥១.៣៧៦គ.ម ក្នុងនោះ ផ្លូវក្នុងខេត្តចំនួន ០៨ខ្សែ ផ្លូវក្រុងចំនួន ៥៩ខ្សែ និងផ្លូវលំចំនួន ៣២ខ្សែ។ ដោយឡែកចំពោះការងារផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ តាមរយៈអង្គភាពរដ្ឋាករទឹកស្អាតរដ្ឋ និងស្ថានីយ៍ទឹកស្អាតឯកជន សម្រេចបានប្រមាណជិត ៩០% និងបណ្តាញផ្គង់ផ្គង់អគ្គិសនីបានគ្របដណ្តប់ស្ទើតែគ្រប់ភូមិទាំងអស់មានចំនួនប្រមាណ ១២.២៨៤ខ្នងផ្ទះ។
- **វិស័យទេសចរណ៍៖** ជាខេត្តដែលមានផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ ប្រជុំភ្នំ ខ្ពង់រាប សំបូរជ្រោះ ជ្រលងជងអូរ គិរីបព្វតា សុទ្ធសឹងតែជាសក្តានុពលទេសចរណ៍មួយ ធ្វើឱ្យខេត្តមណ្ឌលគិរី

ត្រូវបានកំណត់ជាប៉ូលសេដ្ឋកិច្ចទី៤។ ខេត្តមានតំបន់រមណីយដ្ឋានទេសចរណ៍ ១០៥កន្លែង និងរមណីយដ្ឋានទេសចរណ៍ដែល មានសេវាកម្មស្នាក់នៅ និងគ្មានសេវាកម្មស្នាក់នៅ និងតង់ស្នាក់នៅទេសចរណ៍ចំនួន ៣៨កន្លែង។ ដោយក្នុងឆ្នាំ២០២២ ភ្ញៀវទេសចរដែលបានមកទស្សនាខេត្ត មានចំនួនកើនឡើង ២១,៨២%។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានប្តេជ្ញាខិតខំបន្តអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ និងដំណាក់កាលបន្តបន្ទាប់ទៀត ក្នុងន័យរួមចំណែកក្នុងការរក្សាបាននូវសន្តិសុខ ស្ថិរភាពនយោបាយ សង្គម ជំរុញនូវការអភិវឌ្ឍលើគ្រប់វិស័យ ពិសេសការពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងអគ្គិសនីទៅដល់គ្រប់ភូមិទាំងអស់ ព្រមទាំងបង្កើនគុណភាពនៃការផ្តល់សេវាប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព ឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

## IV. សម្គាល់

ខេត្តមណ្ឌលគិរី មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ។ ក្នុងនោះ ការងារគ្រប់គ្រងរដ្ឋបាល ការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ ការងារកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ច ការងារផ្តល់សេវាសាធារណៈ សេវារដ្ឋបាល ការងារគ្រប់គ្រងព្រំដែន និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ការអភិវឌ្ឍសមត្ថភាព ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ការអភិវឌ្ឍវិស័យឯកជន វិស័យការងារ និងវិស័យបណ្តុះបណ្តាល ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងគ្រោះមហន្តរាយ ការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ ការដោះស្រាយទំនាស់ដីធ្លី ក៏កំពុងត្រូវបានធានា និងមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ ធ្វើឱ្យខេត្តទាំងមូលមានការប្រែមុខមាត់ថ្មី ព្រមទាំងបានលើកកម្ពស់ស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរជាលំដាប់៕

ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣